**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការក្រសួងយុត្តិធម៌

លេខ ០៤ សរ-៩៨

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោក ប្រធានតុលាការ និងព្រះរាជអាជ្ញាគ្រប់ខេត្ត ក្រុង**

**សូមជ្រាប។**

***កម្មវត្ថុ:*** អំពីការចោទប្រកាន់យោធិនដែលបានប្រព្រឹត្តខុសច្បាប់ ។

ខ្ញុំសូមផ្ញើភ្ជាប់ជាមួយនេះជូនអស់លោកជ្រាប អំពីនីតិវិធីធ្វើការចោទប្រកាន់យោធិនដែលបានប្រព្រឹត្តខុសច្បាប់នៅក្នុងខេត្ត ក្រុង មួយចំនួនហើយដែលក្រសួងយុត្តិធម៌បានសុំការសហការពីក្រសួងការពារជាតិដើម្បីរួមគ្នារក្សាការពារការគោរពច្បាប់ ការពារសិទ្ធិមនុស្ស និងការពារសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

អំណើះតទៅ បើមានករណីត្រូវចោទប្រកាន់ពីការប្រព្រឹត្តខុសច្បាប់ ឬការអញ្ជើញយោធិនអោយមកកាន់តុលាការ(ក្នុងវិវាទរដ្ឋប្បវេណី) ខ្ញុំសូមអស់លោកសរសេរជាលាយលក្ខ័អក្សរជម្រាបទៅមេបញ្ជាការ ដែលគ្រប់គ្រងគេនៅក្នុងខេត្ត-ក្រុង នោះបានយល់ដឹងអំពីរឿងហេតុ ហើយសូមឱ្យមេបញ្ជាការនោះបញ្ជូនអ្នកប្រព្រឹត្តល្មើសច្បាប់មកតុលាការ ឬក៏ឱ្យចូលមកបំភ្លឺតុលាការក្នុងរឿងវិវាទរដ្ឋប្បវេណី បើមានការរឹងរូសពីសាមីខ្លួនសូមអស់លោកធ្វើអន្តរាគមន៍ជាលាយលក្ខ័អក្សរទៅមេបញ្ជាការ ។

បើមានការរាំងស្ទះពីសំណាក់មេបញ្ជាការវិញ សូមអស់លោកសរសេររបាយការណ៍ទៅក្រសួងយុត្តិម៌ជាបន្ទាន់ ដើម្បីក្រសួងនោះស្រាយបញ្ហានោះជាមួយក្រសួងការពារជាតិ ។

ខ្ញុំសូមអស់លោក មានហើយរក្សាទំនាក់ទំនងសាមគ្គីភាពអោយបានល្អហើយជាប់ជានិច្ចជាមួយអាជ្ញាធរស៊ីវិល និងយោធានៅខេត្ត-ក្រុង ដែលអស់លោកបំពេញភារកិច្ច ។ សាមគ្គីភាពល្អ ហើយជិតស្និត នឹងជួយជំរុញការងារឱ្យទទួលលទ្ធផលចម្រើនជឿនលឿនទៅមុខសម្រាប់សង្គមជាតិយើង។

ធ្វើនៅភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៨

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋន្ត្រី

- ក្រសួងការពារជាតិ